**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៤២២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សាកលវិទ្យាល័យអន្តរជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២ .នស .៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពី ការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពី លក្ខណៈ វិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតស្នើសុំ របស់លោក អ៊ួន សាបូ ចុះថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០០២
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា ១ :** ទទួលស្គាល់ គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា "សាកលវិទ្យាល័យអន្តរជាតិ" "INTERNATIONAL UNIVERSITY" ហៅកាត់ជាភាសាខ្មែរ "ស.អ" និង ហៅកាត់ជាភាសាអង់គ្លេស "I.U" ។ សាកលវិទ្យាល័យនេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួង អប់រំ យុវជន និង កីឡា និងមានទីតាំងគោលស្ថិតនៅអាគារលេខ ៣៥, ៣៧, ៣៩, ៤១ ផ្លូវលេខ ៥៨២ សង្កាត់ បឹងកក់ ២ ខ័ណ្ឌ ទួលគោក រាជធានីភ្នំពេញ ។

**មាត្រា ២ :** សាកលវិទ្យាល័យអន្តរជាតិធ្វើការបណ្តុះបណ្តាល :

- ថ្នាក់បរិញ្ញាប័ត្ររង សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៨០ ក្រេឌីត ជាមធ្យម ។
- ថ្នាក់គិលានុបដ្ឋាកមធ្យម ឆ្មបមធ្យម ឱសថការីមធ្យម សិក្សារយៈពេលយ៉ាងតិច ៣ឆ្នាំ ។
- ថ្នាក់បរិញ្ញាប័ត្រ សិក្សារយៈពេលយ៉ាងតិច ៤ឆ្នាំ ត្រូវនឹង ១៦០ ក្រេឌីត ជាមធ្យម ។

- ថ្នាក់វេជ្ជបណ្ឌិត សិក្សារយៈពេលយ៉ាងតិច ៦ឆ្នាំ ។
- ថ្នាក់ទន្តបណ្ឌិត សិក្សារយៈពេលយ៉ាងតិច ៥ឆ្នាំ ។
- ថ្នាក់ឱសថការីឧត្តម សិក្សារយៈពេលយ៉ាងតិច ៥ឆ្នាំ ។
- ថ្នាក់ម៉ាស្ទ័រ សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៦០ ក្រេឌីត ជាមធ្យម ។
- ថ្នាក់វេជ្ជបណ្ឌិតឯកទេស ទន្តបណ្ឌិតឯកទេស ឱសថការីឯកទេស ដែលមានកំរិតស្មើនឹង ថ្នាក់ម៉ាស្ទ័រត្រូវសិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ បន្ទាប់ពីបានសញ្ញាប័ត្រវេជ្ជបណ្ឌិត ទន្តបណ្ឌិត និង ឱសថការីឧត្តម ឬ បរិញ្ញាប័ត្រឱសថការី ។
- ថ្នាក់បណ្ឌិត សិក្សាស្រាវជ្រាវ រយៈពេលយ៉ាងតិច ៣ឆ្នាំ ។

**មាត្រា ៣ :** សាកលវិទ្យាល័យអន្តរជាតិមាន :

១- មហាវិទ្យាល័យ បច្ចេកវិទ្យា និង វិទ្យាសាស្ត្រ

២- មហាវិទ្យាល័យ មនុស្សសាស្ត្រ និង ភាសា

៣- មហាវិទ្យាល័យ វិទ្យាសាស្ត្រសង្គម និង សារព័ត៌មាន

៤- មហាវិទ្យាល័យ ពាណិជ្ជសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

៥- មហាវិទ្យាល័យ នីតិសាស្ត្រ

៦- មហាវិទ្យាល័យ វិទ្យាសាស្ត្រកសិកម្ម និង អភិវឌ្ឍន៍ជនបទ

៧- មហាវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល

ទៅថ្ងៃអនាគត សាកលវិទ្យាល័យនេះអាចបើកមហាវិទ្យាល័យ ឬ សាខា ឬ ឯកទេស ឬ កំរិត ផ្សេងទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៤ :** សាកលវិទ្យាល័យអន្តរជាតិ មានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារពិនិត្យ និង សំរេច លើគោលនយោបាយ និង ផែនការអភិវឌ្ឍរបស់សាកលវិទ្យាល័យ ហើយមានក្រុមប្រឹក្សាវិទ្យាសាស្ត្រមួយ សំរាប់ពិនិត្យ និង ផ្តល់យោបល់លើ កម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

**មាត្រា ៥ :** លក្ខខណ្ឌទទួលសិស្សអោយចូលរៀន :

- ថ្នាក់បរិញ្ញាប័ត្ររង : បេក្ខជនត្រូវមានចំណេះដឹងទាបបំផុត បានសិក្សាបញ្ចប់ថ្នាក់ទី១២ នៃមធ្យមសិក្សាចំណេះទូទៅ ។
- ថ្នាក់បរិញ្ញាប័ត្រ : បេក្ខជនដែលមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។
- ថ្នាក់ម៉ាស្ទ័រ : បេក្ខជនដែលមានសញ្ញាប័ត្របរិញ្ញា រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។
- ថ្នាក់បណ្ឌិត : បេក្ខជនដែលមានសញ្ញាប័ត្រម៉ាស្ទ័រ រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។
- ចំពោះការចូលរៀននៅក្នុងមហាវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល ត្រូវគោរពតាមបទដ្ឋានរបស់ក្រសួងសុខាភិបាល និង ក្រសួងអប់រំ យុវជន និង កីឡា ដែលកំនត់អំពីលក្ខខ័ណ្ឌនៃការជ្រើសរើសនិស្សិតអោយចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

**មាត្រា ៦ :** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យអន្តរជាតិមានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ ។
- ជ្រើសរើស សិស្ស-និស្សិត អោយចូលរៀននិងជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និងបុគ្គលិកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អ នូវការងារនិស្សិត ការងារសិក្សា ការងារបង្រៀន ការងារស្រាវជ្រាវ និង ការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំរបស់រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។

- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូនក្រសួងអប់រំ យុវជន និង កីឡា អោយបានទៀងទាត់ តាមកាលកំណត់ ។

**មាត្រា ៧ :** និស្សិត ដែលរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យអន្តរជាតិ និង ទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រតាមកំរិត និង តាមឯកទេសដែលបានសិក្សា ។ សញ្ញាប័ត្រនេះត្រូវបានផ្តល់អោយ ដោយសាកលវិទ្យាល័យអន្តរជាតិ ហើយត្រូវបានទទួលស្គាល់ពីក្រសួង អប់រំ យុវជន និង កីឡា ក្នុងករណី សាកលវិទ្យាល័យនេះ បំពេញ និង អនុវត្តបានតាមគោលការណ៍កំនត់របស់ ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និង សាកលវិទ្យាល័យអន្តរជាតិមានភារកិច្ចរៀង១ខ្លួន ដើម្បីអនុវត្តនិងប្រតិបត្តិតាមអនុក្រឹត្យនេះ។

**មាត្រា ៩ :** អនុក្រឹត្យនេះ មានប្រសិទ្ធិភាព និង គតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- សាលាក្រុងភ្នំពេញ
- ឯកសារ-កាលប្បវត្តិ